# សង្គមស៊ីវិលថាសេរីភាពមូលដ្ឋានមិនទាន់ល្អប្រសើរ តែអ្នកនាំពាក្យថាពលរដ្ឋមានសេរីភាពពេញលេញ

ដោយ៖ ថា ចាន់ធី 18-08-2024 5:19 p m




នៅក្នុងសេចក្តីថ្លែងការណ៍រួម របស់អង្គការសង្គមស៊ីវិលចំនួន ១២ស្ថាប័ន ស្តីពី«លទ្ធផលនៃកិច្ចពិគ្រោះយោបល់ លើបញ្ហាប្រឈម ក្តីកង្វល់ និងអនុសាសន៍របស់យុវជន»បានឱ្យដឹងថា សេរីភាពមូលដ្ឋាននៅកម្ពុជា នៅតែមិនទាន់មានភាពល្អប្រសើរនៅឡើយ ដោយរួមមានទាំង សេរីភាពសមាគម សេរីភាពការជួបប្រជុំ និងសេរីភាពការបញ្ចេញមតិជាដើម។ ទន្ទឹមនឹងការលើកឡើងនេះ អង្គការសង្គមស៊ីវិលទាំងអស់ខាងលើ ក៏ស្នើដល់រាជរដ្ឋាភិបាលកម្ពុជា គួរផ្តល់ឱកាសដល់យុវជនចូលរួមកិច្ចការសង្គមដោយគ្មានការភ័យខ្លាច និងបើកលំហរសេរីភាពឱ្យយុវជនសម្តែងមតិ ព្រោះតែសង្កេតឃើញថា កន្លងមកមានអ្នកធ្វើការផ្នែកសិទ្ធិមនុស្ស អ្នកការពារបរិស្ថាន និងសកម្មជនកិច្ចការសង្គមមួយចំនួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងបញ្ជូនទៅកាន់តុលាការ។

ឆ្លើយតបទៅនឹងការលើកឡើងរបស់អង្គការសង្គមស៊ីវិល លោក ប៉ែន បូណា អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់តាមរយៈវិទ្យុវាយោថា បច្ចុប្បន្ន សេរីភាពរបស់ពលរដ្ឋទូទៅគឺជាសេរីភាពមានលក្ខណៈពេញលេញ ហើយពលរដ្ឋទូទាំងប្រទេស ជាពិសេសយុវជន បាននឹងកំពុងចូលរួមសកម្មភាពជួយសង្គមយ៉ាងច្រើនកុះករ និងគ្រប់វិស័យ ដោយគ្មានការភ័យខ្លាច លើកលែងតែមួយចំនួនតូច ដែលធ្វើសកម្មភាពខុសច្បាប់។

ចំពោះការឃាត់ខ្លួនបុគ្គលមួយចំនួនវិញ ដាក់ស្តែងដូចជា សកម្មជនបរិស្ថានជាដើម ត្រូវបានអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជាបញ្ជាក់ជូនមកកាន់អង្គការសង្គមស៊ីវិលថា សូមកុំយកមកលូកឡំ ហើយគិតថានោះគឺជាការរឹតត្បិតសេរីភាពបញ្ចេញមតិ តែវាជាការបំពានច្បាប់ និងអំពាវនាវឱ្យសង្គមស៊ីវិលទាំងឡាយជួយបង្រៀននិងផ្សព្វផ្សាយដល់ពលរដ្ឋនិងយុវជនឬសង្គមស៊ីវិលខ្លួនឯងឱ្យចេះធ្វើការសម្តែងមតិយ៉ាងណានៅក្នុងក្របខណ្ឌច្បាប់ និងគោរពសិទ្ធិគ្នាទៅវិញទៅមក។

នៅសេចក្តីថ្លែងរបស់អង្គការសង្គមស៊ីវិលទាំង ១២ស្ថាប័នបានបញ្ជាក់បន្ថែមថា យោងតាមរបាយការណ៍ស្តីពី សេរីភាពមូលដ្ឋានរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR)ឆ្នាំ២០២៣ បានបង្ហាញថា មានហេតុការណ៍ចំនួន ៧១៤ ដែលក្នុងនោះគឺប៉ះពាល់សេរីភាពសមាគមចំនួន ៣៤៤ហេតុការណ៍ សេរីភាពជួបប្រជុំ ១៣៤ហេតុការណ៍ និងសេរីភាពបញ្ចេញមតិ ចំនួន ២៣៨ហេតុការណ៍ ពាក់ព័ន្ធនឹងការរឹតត្បិត និងរំលោភបំពាន៕ ដោយ៖ថា ចាន់ធី